ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

សំណុំរឿង

លេខ : ០៤៣/០០៥/២០០១

ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១

**សេចក្តីសំរេច**

លេខ : ០៤៣/០០៥/២០០១ កបធ.ច

ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០១

# ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតប្រធានរដ្ឋសភាលេខ ៤៨៥ រ.ស ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១ ស្នើឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃការធ្វើវិសោធនកម្មមាត្រា ៣ នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០១ នាសម័យប្រជុំរដ្ឋសភាលើកទី ៦ នីតិកាលទី ២ ហើយព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់នៅថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៥ នីតិកាលទី ១ ដោយយល់ស្របតាមលើទម្រង់ និងគតិនៃច្បាប់ទាំងស្រុងគ្មានកែប្រែអ្វីឡើយ ហើយដែលក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១
- បានឃើញសេចក្តីសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ ០៤០ / ០០២ / ២០០១ កបធ.ប ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០១ បានប្រកាសថា " *ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ* " ស្របនឹងរដ្ឋធម្មនុញ្ញ លើកលែងតែបទបញ្ញត្តិទាំងឡាយដែលបានចែងថា " ... *ត្រូវទានទោសឧក្រិដ្ឋថ្នាក់ទីពីរ* " ដែលជាទោសសម្រាប់ក្នុងមាត្រា ២០៩ . ៥០០ . ៥០៦ និង ៥០៧ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ដែលត្រូវបានចង្អុលក្នុងមាត្រា ៣ នៃច្បាប់នេះ

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

-យល់ឃើញថា រដ្ឋសភា និងព្រឹទ្ធសភា បានអនុម័តយ៉ាងត្រឹមត្រូវតាមបែបបទ ដែលមានចែងក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យអនុម័តការធ្វើនិយតកម្មមាត្រា ៣ នៃច្បាប់នេះ

-យល់ឃើញថា រដ្ឋសភាបានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ វាក្យខណ្ឌទី ២ ក្នុងការបញ្ជូនមកឱ្យក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យមុននឹងច្បាប់នេះត្រូវបានប្រកាសឱ្យប្រើ

-យល់ឃើញថា ការធ្វើនិយតកម្មមាត្រា ៣ នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ បានឆ្លើយតបជាវិជ្ជមានទៅនឹងការកត់សំគាល់របស់ក្រុមប្រឹក្សាធម្មនុញ្ញក្នុងសេចក្តីសំរេចលេខ ០៤០/០០២/២០០១ ក.ប.ធ.ច ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០១

**សំរេច**

**មាត្រា ១** - ផ្អែកតាមមូលបទខាងលើ មាត្រា ៣ នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដែលរដ្ឋសភាបានអនុម័តយល់ព្រមធ្វើនិយតកម្ម កាលពីថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០១ នាសម័យប្រជុំរដ្ឋសភាលើកទី ៦ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់កាលពីថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៥ នីតិកាលទី ១ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២** - សេចក្តីសំរេចនេះ ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ និងជាសេចក្តីសំរេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០១

**ជ. ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

ប៊ិន ឈិន